00177504

**Declassified to Public**
**06 September 2012**

ERN/No A 80/I

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires aux seins des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

| ឯកសារដើម |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 04 / 2008 |
| ម៉ោង (Time/Heure): 08 h 30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal |

**<u>គោរពជូន</u>**

**លោក François PONCHAUD**
**មជ្ឈមណ្ឌលកាតូលិកកម្ពុជា**
**ផ្ទះលេខ៥៧ ផ្លូវ១០១ បឹងត្របែក**
**ភ្នំពេញ**

ព្រះអង្គជាទីគោរព!

យើងខ្ញុំបានទទួលរួចមកហើយនូវលិខិតរបស់ព្រះអង្គចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ ដែលស្នើសុំការអនុញ្ញាតចូលសួរសុខទុក្ខ និងប្រគល់គម្ពីរប៊ីបដល់ជនជាប់ឃុំឃាំង **កាំង ហ្គេកអ៊ាវ**។

សំណើរបស់ព្រះអង្គអាចចោទជាបញ្ហាមួយ។ ដោយផ្អែកលើដំណើរជីវិតព្រះអង្គផ្ទាល់នៅប្រទេសកម្ពុជា យើងខ្ញុំយល់ឃើញថាវាមានសារៈសំខាន់ណាស់ក្នុងគម្រោងយកចម្លើយសាក្សីរបស់យើងពីព្រះអង្គក្នុងជានាមសាក្សី នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតដែលកំពុងដំណើរការប្រឆាំងនឹង **នួន ជា អៀង សារី ខៀវ សំផន** និងជនត្រូវចោទដ៏ទៃទៀត។ ផ្ទុយទៅវិញ ការយកចម្លើយសាក្សី (កាលបរិច្ឆេទនៃការយកចម្លើយសាក្សីមិនទាន់អាចកំណត់បាននៅឡើយទេ) នឹងបាត់បង់កិត្យានុភាពរបស់វា ប្រសិនបើព្រះអង្គមានលទ្ធភាពប្រាស្រ័យទាក់ទងជាមុនជាមួយឌុច។ ទោះបីជាព្រះអង្គមិនលើកឡើងពីអ្វីទាក់ទងនឹងអង្គហេតុដែលជាចំណាត់ការរបស់កិច្ចការស៊ើបអង្កេត នៅពេលសួរសុខទុក្ខនេះក៏ដោយ ក៏សកម្មភាពសំដែងឲ្យឃើញបែបនេះជាបញ្ហាមិនល្អមួយរួចទៅហើយ។

| ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|
| CERTIFIED COPY/COPIE CERTIFIÉE CONFORME |
| ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 04 / 2008 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal |

Original FR: 00166617-00166617

ឯកសារ A 80/I

កាលពីសប្តាហ៍មុន ជនជាប់ឃុំបានផ្ញើរលិខិតមួយដើម្បីជូនដំណឹងដល់យើងខ្ញុំអំពីបំណងរបស់គាត់ក្នុងការទទួលយកដំណើររមកសួរសុខទុក្ខរបស់លោក «Betombes បព្វជិតប្រចាំកម្ពុជា ឬ បព្វជិតណាមួយចាត់តាំងដោយលោកBetombes»។ យើងខ្ញុំបានជម្រាបគាត់រួចហើយថា យើងនឹងផ្តល់ការអនុញ្ញាតឲ្យគាត់ទទួលជួបអ្នកមកសួរសុខទុក្ខបាន បន្ទាប់ពីអ្នកមកសួសុខទុក្ខនោះទទួលបានការអនុញ្ញាតពីយើង។

អាស្រ័យដោយមូលហេតុដូចបានរៀបរាប់ខាងលើ យើងខ្ញុំយល់ថា ព្រះអង្គគួរចាត់តាំងបព្វជិតណាម្នាក់ផ្សេងក្រៅពីរូបព្រះអង្គផ្ទាល់មកសួរសុខទុក្ខ ឌុច។

យើងខ្ញុំយល់ថាវាមិនមែនជារឿងមិនល្អនោះទេ ប្រសិនបើព្រះអង្គអាចឲ្យនរណាម្នាក់យកគម្ពីរប៊ីបសរសេរដោយដៃព្រះអង្គទៅឲ្យជនជាប់ឃុំឃាំងនោះ។

សូមព្រះអង្គមេត្តាទទួលយកនូវភាពរាក់ទាក់ដ៏ជ្រៀលជ្រៅអំពីយើងខ្ញុំ។

យូ ប៊ុនឡេង Marcel LEMONDE